# ប្រកាសលេខ

# ៤៨៤

# ស្តីពីពន្លឺនិងការ

# បំភ្លឺ

www.ekasar.com



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ៤៨៤ ស.ក.ប.យ រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ពន្លឺនិងការបំភ្លឺ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

**ប្រការ១.-** និយោជក នៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារត្រូវរៀបចំយ៉ាងណាឱ្យអគារ រោងជាង ទីកន្លែងធ្វើការ មានពន្លឺធម្មជាតិ និងពន្លឺសិប្បនិម្មិតសមស្របទៅនឹងការងារ គឺលៃលកយ៉ាងណាធានាឱ្យកម្មករនិយោជិត សំឡឹងមើលឃើញបានច្បាស់និងមិនរោយភ្នែក ។ ការបំភ្លឺជាទូទៅ ត្រូវបានបន្ថែមដោយការបំភ្លឺជាលក្ខណៈដោយឡែក នៅតាមមណ្ឌលធ្វើការ ឬប៉ុស្តិការងារ ។

ពាក្យបច្ចេកទេសទាំងឡាយមានពន្យល់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-** ការផ្តល់ពន្លឺសំរាប់ការងារប្រណិត ឬការងារផ្ចិតផ្ចង់ ត្រូវធ្វើយ៉ាងណាឱ្យការសំឡឹងមើលមិនឿយហត់និងមិនបង្កឱ្យមានបច្ច័យមិនល្អទៅអនាគត ពិសេសគឺ ៖

- ពន្លឺដែលបំភ្លឺមណ្ឌលធ្វើការ ត្រូវឱ្យមានកំរិតប្រហាក់ប្រហែលនិងមណ្ឌលជិតខាងនោះ
- ការបំភ្លឺជាទូទៅនៅទីកន្លែងធ្វើការតែមួយ ត្រូវយ៉ាងហោចណាស់ស្មើនឹង មួយភាគប្រាំ នៃការបំភ្លឺមណ្ឌលធ្វើការ ឬប៉ុស្តិការងារ
- ការបំភ្លឺ ត្រូវមានគុណភាពអាចមើលឃើញពណ៌បានត្រឹមត្រូវ សមស្របជាមួយនឹងសកម្មភាពនៃការងារ
- កម្មករនិយោជិតត្រូវបានការពារទប់ទល់និងប្រភពពន្លឺដែលចាំងខ្លាំង ទោះដោយត្រង់ឬដោយប្រយោលក្តី
- បាតុភូតនៃពន្លឺភ្លឺបភ្លែត ត្រូវលុបបំបាត់
- ប៉ុស្តិការងារមិនត្រូវទទួលកាំរស្មីព្រះអាទិត្យដោយផ្ទាល់ឡើយ ។

**ប្រការ៣.-** កំរិតបំភ្លឺជាមធ្យមនៅមណ្ឌលធ្វើការ ឬនៅប៉ុស្តិការងារ ត្រូវបានកំណត់ក្នុងតារាងជាបន្តបន្ទាប់ដូចខាងក្រោមនេះ ៖

| មណ្ឌលធ្វើចរាចរ និងសន្និធិ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| មណ្ឌលធ្វើចរាចរ | 100 – 150 |
| ជណ្តើរ | 150 |
| គីរង់ានដុកទំនិញ | 150 |
| ឃ្លាំងសន្និធិ | 100 |

| ទីកន្លែងបំរុងសំរាប់កម្មករនិយោជិត | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| អាហារដ្ឋាន | 200 |
| កន្លែងទុកសំលៀកបំពាក់ | 100 |
| បង្គន់ - បន្ទប់ទឹក | 100 |
| គិលានដ្ឋាន | 500 |

| ឧស្សាហកម្មម្ហូបអាហារ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការដុសលាង និងបំពេញធុង | 200 |
| ការជ្រើសរើស និងវេចខ្ចប់ | 200 |
| ការបញ្ចូលក្នុងកំប៉ុងឬដប | 500 |
| ការពិនិត្យបញ្ជាក់លើកែវឬដប | 500 |
| ការត្រួតពិនិត្យផលិតផល | 500 |
| ការត្រួតពិនិត្យពណ៌ | 1000 |

| ឧស្សាហកម្មថ្នាំជក់ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការងារសំងួត | 200 |
| ការងារជ្រើសរើស | 1000 |
| ផលិតកម្មបារី | 500 |

| ឧស្សាហកម្មឈើ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការប្លែងភាពជាស្វ័យប្រវត្តិ | 100 |
| ការងារនៅរណ្តៅចំហាយ | 150 |
| ការងារជាងឈើ ( កាត់ ច្រៀក ឈូស ... ) | 500 |
| ការខាត់ លាប កោសសំអាត | 500 |
| ការងារជ្រើសរើស | 750 |
| ការងារចម្លាក់ | 750 |
| ការត្រួតពិនិត្យគុណភាព | 750 |

| ឧស្សាហកម្មកញ្ចក់ ចាន ត្រីស្តាល់ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការងារសំងួត | 100 |
| ការត្រៀម ឃ្លាំមើលគ្រឿងចក្រ | 300 |
| ការវាយថ្នាំភ្លឺ• ការកិនសំប៉ែត ចាក់ពុម្ព ... | 750 |
| ការងារសំលៀង ឆ្លាក់ ដោយដៃ | 750 |
| ការងាររចនាគំនូរ | 750 |
| ការផលិតត្រីស្តាល់ | 1500 |

www.ekasar.com



| ឧស្សាហកម្មគីមី | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការកិនកំទេច លាយ | 300 |
| ការកិនសំប៉ែត ម៉ាស៊ីនបាញ់ខ្យល់ | 500 |
| ការងារផលិតកៅស៊ូកង់ | 500 |
| បន្ទប់បញ្ជា | 500 |
| មន្ទីរពិសោធន៍ | 500 |
| ការត្រួតពិនិត្យពណ៌ | 1000 |

| ឧស្សាហកម្មផលិតបរិក្ខារអគ្គីសនី | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការផលិតខ្សែកាបនិងខ្សែភ្លើង | 300 |
| ការរុំបូប៊ីនធំ | 300 |
| ការរុំបូប៊ីនមធ្យម | 500 |
| ការរុំបូប៊ីនតូច | 750 |
| ការលាបថ្នាំលើបូប៊ីន | 300 |
| ការពាសសំណប៉ាហាំង | 300 |
| ការងារផ្គុំបរិក្ខារ ធំ មធ្យម តូច | 300 - 500 - 750 |
| ការផលិតបរិក្ខារតូចៗសំរាប់វាស់វែង | 1000 |
| រោងជាងអេឡិចត្រូនិច | 1500 |

| បោះពុម្ព | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការកាត់ក្រដាស់ លាបទឹកមាស ធ្វើប្លុក ធ្វើពុម្ព | 500 |
| ការរៀបអក្សរ | 500 |
| ការផ្គុំចំរុះ ជួសកែសំរួល | 1000 |
| សិលាលេខ | 1000 |
| ការត្រួតពិនិត្យពណ៌ | 1500 |
| ការចងសៀវភៅ | 500 |

www.ekasar.com



| វាយនភណ្ឌ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការសិត ហូត ទាញអំបោះ | 300 |
| ការវៃអំបោះ ស្រាវអំបោះ ការហុងអំបោះ | 500 |
| ការអន្ទង ត្បាញ ចាក់ | 750 |
| ការបង្ហើយ ជ្រលក់ពណ៌ | 500 |
| បន្ទប់សំងួត | 100 |
| ការបោះពុម្ពជាស្វ័យប្រវត្តិ | 500 |
| ការត្រួតពិនិត្យពណ៌ | 1000 |

| ឧស្សាហកម្មសម្លៀកបំពាក់ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការបាក់ តំឡើងក្រឡាចាក់ | 750 |
| ការតំឡើងពុម្ពកាត់ និងកាត់ | 750 |
| ការស្រេះ | 1500 |
| ការដេរ | 1000 |
| ការអ៊ុត | 300 |
| ការត្រួតពិនិត្យចុងក្រោយ | 1000 |

| ផលិតគ្រឿងអលង្ការ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| ការងារច្នៃត្បូង | 1500 |
| ការធ្វើនិងតំឡើងគ្រឿងអលង្ការ | 1000 |
| ការធ្វើនិងតំឡើងនាឡិកាដៃ | 1500 |

www.ekasar.com



| សណ្ឋាគារ ភោជនីយដ្ឋាន | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| កន្លែងបដិសណ្ឋារកិច្ច បេឡា គេហបាល | 300 |
| ផ្ទះបាយ | 500 |
| បន្ទប់បាយ ភោជនីយដ្ឋាន | 200 |
| របៀង | 100 |

| អគាររដ្ឋបាល ការិយាល័យ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| កន្លែងរៀបចំទុកដាក់ | 300 |
| កន្លែងសរសេរ អង្គុលីលេខ អាន វិភាគទិន្នន័យ | 500 |
| បន្ទប់កុំព្យូទ័រ | 500 |
| កន្លែងគូរគំនូរឧស្សាហកម្ម | 1000 |
| បន្ទប់ប្រជុំ | 500 |
| កន្លែងបដិសណ្ឋារកិច្ច | 300 |
| កន្លែងទុកដាក់ឯកសារ | 200 |

| ភណ្ឌាគារ ឃ្លាំង ហាងលក់រាយ | ការបំភ្លឺជាមធ្យមគិតជាលុច ( lux ) |
|---|---|
| កន្លែងដាក់លក់ | 300 |
| កន្លែងបេឡា | 300 |
| កន្លែងវេចខ្ចប់ | 500 |

ប្រការ៤.- និយោជកត្រូវរៀបចំយ៉ាងណា កុំឱ្យកម្មករនិយោជិតមានការរំខានដោយសារកំដៅដែលសាយភាយចេញពីប្រភពបញ្ចេញពន្លឺ ឬបណ្តាលឱ្យមានការរលាកដោយសារប្រភពកំដៅនោះ ។ ទីបិទបើកសំរាប់ការបំភ្លឺ ត្រូវមានភាពងាយស្រួល ទោះបន្ទប់ស្ថិតក្នុងភាពងងឹតក៏ដោយ ។ ប្រព័ន្ធរួមនៃការបំភ្លឺ (ខ្សែភ្លើង ដើងចាប់អំពូល កុងតាក់) ត្រូវរៀបចំឱ្យបានរឹងមាំតាមលក្ខណៈបច្ចេកទេស ដើម្បីជៀសវាងកុំឱ្យឆក់ ។

www.ekasar.com



**ប្រការ៥.** - ម៉ាស៊ីនភ្លើង ត្រូវដាក់ឱ្យនៅឆ្ងាយពីទីកន្លែងធ្វើការ ឬអគារដទៃទៀតសំរាប់កម្មករនិយោជិតប្រើប្រាស់ ដើម្បីជៀសវាងប្រភពសំឡេងខ្លាំង ឬការបំពុលបរិយាកាស ។

**ប្រការ៦.-** និយោជក ត្រូវរៀបចំដាក់ឱ្យមានភ្លើងបំភ្លឺជំនួយបំរុង សំរាប់បំភ្លឺពេលដាច់ចរន្តធម្មតា ។ ភ្លើងបំភ្លឺជំនួយបំរុងនេះ ត្រូវឱ្យមានកំរិតយ៉ាងតិច ៥លុច ។

**ប្រការ៧.-** ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុង ជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ

www.ekasar.com


ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៨៤ សកបយ.
ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីពន្យល់ពាក្យបច្ចេកទេស

| ពាក្យខ្មែរ | ជាភាសាបារាំង | សេចក្តីពន្យល់ |
|---|---|---|
| មណ្ឌល | Zone | ទីកន្លែង ចំណុច |
| មណ្ឌលធ្វើការ | Zone de travail | ចំណុចបុំស្តិ៍ការងារ |
| មណ្ឌលជិតខាង | Zone contiguë | ទីកន្លែងដែលនៅជុំវិញមណ្ឌលធ្វើការ |
| លុច | Lux | បរិមាណប្រើយកជាខ្នាតសំរាប់វាស់ពន្លឺ |
| បាតុភូតនៃពន្លឺភ្លឺបភ្លែត | Phénomènes de fluctuation (Effets stroboscopiques) | ភ្លើងបំភ្លឺដែលឆេះរលត់ៗ |
| ឃ្លាំងសន្និធិ | Magasins de stockage | ឃ្លាំងទុកដាក់ទំនិញបំរុង |
| តំរដ្ឋានផ្ទុកទំនិញ | Quais de chargement | ចន្លោះផ្លូវដែលមានគំនរទំនិញនៅសងខាង |
| ការប្តូរភាពជាស្វ័យប្រវត្តិ | Transformation automatique | ជាខ្សែសង្វាក់ផលិតកម្មស្វ័យប្រវត្តិ |
| គ្រីស្តាល់ | Cristal | វត្ថុធ្វើពីកែវចរណៃ |
| ការវាយថ្នាំភ្លឺ | Emaillage | ការលាបថ្នាំជាតិ Email |
| ធ្វើឃ្លីសេ | Gravure des clichés | ធ្វើពុម្ពដែលឆ្លាក់ផ្ចាប់នឹងក្តារបន្ទះ |
| សិលាលេខ | Lithographie | សិល្បៈខាងការផ្តិតដោយប្រើពុម្ពថ្ម |
| គេហបាល | Concierge | អ្នកស៊ីឈ្នួលយាមផ្ទះឬសណ្ឋាគារ |
| របៀង | Couloirs | ល្វែងតូចនៅពីក្រោយជញ្ជាំងផ្ទះធំ |
| ភ្លើងបំភ្លឺជំនួយបំរុង | Eclairage de sécurité | ភ្លើងបំភ្លឺនៅពេលចរន្តធម្មតាត្រូវកាត់ផ្តាច់ |

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣